**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង អង្កេតស្រាវជ្រាវករណី នាវាឈ្មោះ WINNER

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** .

បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីអង្កេតស្រាវជ្រាវ ករណីនាវាឈ្មោះ WINNER ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ឧត្តមសេនីយ៍ទោ នេត្រ សាវឿន | ប្រធាននាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ ក្រសួងមហាផ្ទៃ | **ប្រធាន** |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ទោ សុខ ផល | ប្រធាននាយកដ្ឋានពត៌មានទូទៅ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៣-លោក ឧត្តមសេនីយ៍ត្រី សៅ វ៉ានី | ប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៤-លោក ឧត្តមសេនីយ៍ត្រី មៀច សុផាន់ណា | ប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ | **សមាជិក** |

| | | |
|---|---|---|
| ៥-លោក គាំង លាងចំណ្ណ | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក ខិម តារារិទ្ធ | ប្រធានការិយាល័យច្បាប់ នាយកដ្ឋានទីតិកម្ម ក្រសួងពាណិជ្ជកម្ម | សមាជិក |

**ប្រការ ២ .-**

គណៈកម្មការចំរុះអន្តរក្រសួងនេះ មានភារកិច្ច :

-ពិនិត្យ ស្រាវជ្រាវនៅក្នុងក្រុមហ៊ុន CAMBODIA SHIPPING CORPORATOIN(CSC) នូវឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងការចុះបញ្ជីឈ្មោះនាវា និងការអនុញ្ញាតអោយដាក់ទង់ជាតិកម្ពុជា ។ មានប៉ុន្មានគ្រឿងដែលបានចុះបញ្ជី ។

-ពិនិត្យ ស្រាវជ្រាវឯកសារផ្សេងៗពាក់ព័ន្ធនឹងការបង់ពន្ធ និងការបង់ចំណូលផ្សេងទៀត ប្រសិនបើមាន ចូលថវិការដ្ឋ ក្នុង១ឆ្នាំៗ បានប៉ុន្មាន ។

-ពិនិត្យ ស្រាវជ្រាវលក្ខណៈវិនិច្ឆ័យដែលបានកំណត់សំរាប់នាវានីមួយៗ ដើម្បីអាចចុះបញ្ជី និងអនុញ្ញាតអោយដាក់ទង់ជាតិកម្ពុជាបាន ។

-ទំនាក់ទំនងជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន សុំបញ្ជីឈ្មោះនាវាធំៗទាំងអស់ ដែលក្រសួងបានចុះបញ្ជី និងអនុញ្ញាតអោយដាក់ទង់ជាតិកម្ពុជា ។

-ក្រោយពីប្រមូលបានពត៌មានសព្វគ្រប់ គណៈកម្មការត្រូវប្រជុំវាយតំលៃ រួចរាយការណ៍លទ្ធផលការងាររបស់ខ្លួន ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដើម្បីរាយការណ៍បន្តជូនសម្តេចនាយករដ្ឋមន្ត្រី ពិនិត្យ និងមានវិធានការតាមការជាក់ស្តែង ។

**ប្រការ ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងសមាសភាពដូចមានចែងក្នុងប្រការ១ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២

ស ខេង

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ ✓